ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខៈ ១៥......../២០១៧អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃពុធ **ទី០១ ខែកុម្ភៈ ឆ្នាំ២០១៧** វេលាម៉ោង **០៨:៣០នាទី** នៅសាលប្រជុំអគារ«ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាជំនុំជម្រះនៃក្រុមប្រឹក្សាធម្មនុញ្ញបានបើកសវនាការជំនុំជម្រះជាសាធារណៈលើ ៖

១-សំនុំរឿងលេខ២៧១/០០៩/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធការសុំលុបឈ្មោះ ធុច សូនី ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ នៅឃុំត្រែងត្រយឹង។

២-សំនុំរឿងលេខ២៧២/០១០/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដិសេធការសុំលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតចំនួន ១០ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ នៅសង្កាត់ចោមចៅ។

៣-សំនុំរឿងលេខ២៧៣/០១១/២០១៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធការសុំលុបឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតចំនួន ០៣ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ នៅឃុំត្រែងត្រយឹង។

ហើយបានចេញសេចក្តីសម្រេចលេខ ១៦៣/០០៣/២០១៧ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ដោយបានតម្កល់សេចក្តីសម្រេចលេខ ០១៥ គ.ជ.ប,០១៦ គ.ជ.បចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ និងសេចក្តីសម្រេចលេខ ០១៩ គ.ជ.ប ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ